# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៥៧. សសរ

## សេចក្តីសម្រេច

## ស្តីពី

## ការបង្កើតគណៈកម្មាធិការដើម្បីរៀបចំកិច្ចប្រជុំ រដ្ឋមន្ត្រីការបរទេសអាស៊ាន (AMM) កិច្ចប្រជុំវេទិកាតំបន់អាស៊ាន (ARF) និងកិច្ចប្រជុំជាមួយប្រទេសដៃគូ (PMC) ឆ្នាំ ២០០៣

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ

## សម្រេច

**ប្រការ ១** : បង្កើតគណៈកម្មាធិការដើម្បីរៀបចំកិច្ចប្រជុំរដ្ឋមន្ត្រីការបរទេសអាស៊ាន កិច្ចប្រជុំវេទិកាតំបន់អាស៊ាន និងកិច្ចប្រជុំជាមួយប្រទេសដៃគូ ឆ្នាំ ២០០៣ ដែលមានសមាសភាពដូចខាងក្រោម :

| | | |
|---|---|---|
| ១. ឯកឧត្តម **ហោ ណាំហុង** | ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ | ប្រធាន |
| ២. ឯកឧត្តម **ហុក ឡងឌី** | អគ្គស្នងការនគរបាលជាតិ ក្រសួងមហាផ្ទៃ | អនុប្រធាន |
| ៣. ឯកឧត្តម **ជា សុផារ៉ា** | ប្រតិភូរាជរដ្ឋាភិបាល ទទួលបន្ទុកអភិបាលរាជធានីភ្នំពេញ | អនុប្រធាន |
| ៤. ឯកឧត្តម **មិន ឃិន** | អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការអចិន្ត្រៃយ៍រៀបចំបុណ្យជាតិនិងអន្តរជាតិ | អនុប្រធាន |
| ៥. ឯកឧត្តម **ខៀវ កាញារីទ្ធ** | រដ្ឋលេខាធិការក្រសួងពត៌មាន | សមាជិក |
| ៦. ឯកឧត្តម **អ៊ុក រ៉ាប៊ុន** | រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ៧. ឯកឧត្តម **សៅ សុខា** | មេបញ្ជាការកងរាជអាវុធហត្ថលើផ្ទៃប្រទេស | សមាជិក |
| ៨. ឯកឧត្តម **ម៉ែម ម៉ីឡា** | អគ្គលេខាធិការ ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ | សមាជិក |

៩. ឯកឧត្តម **ហោ សុធន** អគ្គលេខាធិការរងក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ សមាជិក

១០. លោក **សឹម សុផល** ប្រធាននាយកដ្ឋានអង្គរក្ស ក្រសួងមហាផ្ទៃ សមាជិក

១១. លោកស្រី **ឡុច ផាន់នី** ប្រធាននាយកដ្ឋាន ហិរញ្ញវត្ថុ-គណនេយ្យ ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ សមាជិក

**ប្រការ ២** : គណៈកម្មាធិការរៀបចំកិច្ចប្រជុំនេះ *ប្រើប្រាស់លេខាធិការដ្ឋានអាស៊ានជាតិ ជាសេនាធិការ* ។

**ប្រការ ៣** : គណៈកម្មាធិការរៀបចំកិច្ចប្រជុំនេះមានភារកិច្ចដូចតទៅ :

ក- រៀបចំកម្មវិធីនៃកិច្ចប្រជុំនិងពិធីការអោយសមស្រប

ខ- រៀបចំគំរោងថវិកាក្នុងការរៀបចំកិច្ចប្រជុំនេះ រួចលើកសំណើសុំការសំរេចពីរាជរដ្ឋាភិបាល

គ- សំរបសំរួលរៀបចំការពារសន្តិសុខជូនគណៈប្រតិភូ និងសមាជិកអង្គប្រជុំអោយបានសុវត្ថិភាពល្អ

ឃ- ទទួលបន្ទុកចាត់ចែងសំដែងសិល្បៈរបាំប្រពៃណី ជូនគណៈប្រតិភូក្នុងលក្ខណៈជាតិ និងអន្តរជាតិ ។

ង- ជួយសំរបសំរួលនិងចាត់ចែងលើការធ្វើដំណើរទស្សនាចរណ៍ដល់គណៈប្រតិភូ ក្រោយកិច្ចប្រជុំចប់តាមកម្មវិធីដែលបានកំណត់ ។

ច- ជួយសំរបសំរួល ជាមួយប្រព័ន្ធឃោសនាជាតិ និងអន្តរជាតិ ដើម្បីធ្វើការផ្សព្វផ្សាយកិច្ចប្រជុំនេះ ។

**ប្រការ ៤** : គណៈកម្មាធិការនេះមានសិទ្ធិអញ្ជើញមន្ត្រីជំនាញនៃក្រសួង និងស្ថាប័នពាក់ព័ន្ធនានា មកចូលរួមប្រជុំ ដើម្បីពិភាក្សា និងដោះស្រាយការងារផ្សេងៗដែលចាំបាច់ ។

**ប្រការ ៥** : គណៈកម្មាធិការនេះមានសិទ្ធិបង្កើតអនុគណៈកម្មាធិការជំនាញផ្សេងៗទៀតតាមការចំបាច់ ។

**ប្រការ ៦** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការអចិន្ត្រៃយ៍រៀបចំបុណ្យជាតិនិងអន្តរជាតិ រដ្ឋមន្ត្រី រដ្ឋលេខាធិការនៃក្រសួងស្ថាប័នពាក់ព័ន្ធ និងឯកឧត្តមដែលមានឈ្មោះក្នុងប្រការ ១ ខាងលើ ត្រូវអនុវត្តសេចក្តីសំរេចនេះអោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ ធ្នូ ឆ្នាំ ២០០២

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ ៦
- ឯកសារ កាលប្បវត្តិ